**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តីជាទីគោរពដ៏ខ្ពង់ខ្ពស់**!

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានបីតិសោមនស្សរីករាយ និងសូមអបអរសាទរយ៉ាងកក់ក្តៅ ក្នុងឱកាសដែលព្រះករុណាព្រះបាទបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារជា **សម្តេចវិបុលសេនាភក្តី** ជូនចំពោះសម្តេចប្រធានព្រឹទ្ធសភា។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការគោរពដោយស្មោះចំពោះ **សម្តេច** ដែលបានយកអស់កម្លាំងកាយចិត្តដឹកនាំស្ថាប័នព្រឹទ្ធសភា និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេច** ដែលរយៈពេលកន្លងមកក៏ដូចក្នុងពេលបច្ចុប្បន្ន **សម្តេច** បាននឹងកំពុងដឹកនាំស្ថាប័ននីតិប្បញ្ញត្តិ ទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់ ដែលធ្វើឲ្យយើងខ្ញុំទាំងអស់គ្នាមានជំនឿជឿជាក់ដោយក្តីសង្ឃឹម និងមោទនភាពជាទីបំផុត។

ជាថ្មីម្តងទៀតយើងខ្ញុំ សូមបួងសួងដល់ទេវតាឆ្នាំថ្មី ឆ្នាំមមែ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកនាំមកនូវសិរីសួស្តី ជ័យមង្គល វិបុលសុខជូនចំពោះ **សម្តេចវិបុលសេនាភក្តី និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលសេនាភក្តី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

**ប្រាក់ សុខុន**
**រដ្ឋមន្ត្រី និងជាតំណាងមន្ត្រីរាជការ**
**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**